ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ៣៣០ ស.ក.ប.យ

ភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០០

# ប្រកាសរួម
## ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
## និង ក្រសួងសុខាភិបាល
## ស្តីពី ការរៀបចំគិលានដ្ឋានសហគ្រាស

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០-១១-១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០-៧-១៩៩៤ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣-៣-១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩-០៦ ចុះថ្ងៃទី១៧-៦-១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤-០១-៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី០៤-១០-១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២-១០-៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

## សំរេច

ប្រការ១.- និយោជក នៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុង មាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានកម្មករនិយោជិតចាប់ពី៥០នាក់ឡើងទៅ ត្រូវរៀបចំឱ្យមានគិលានដ្ឋានអចិន្ត្រៃយ៍មួយនៅក្នុងសហគ្រាសរបស់ខ្លួន ។

គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានពេទ្យការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។/.

គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវបានកំណត់តាមលក្ខខ័ណ្ឌនៃ ទីតាំងនិងទំហំ ចំនួននិងគុណភាព បុគ្គលិកសុខាភិបាល ហើយនិងសំភារៈ បរិក្ខារពេទ្យ ព្រមទាំងឱសថ ។

## ប្រការ២.- អំពីទីតាំងនិងទំហំ

គិលានដ្ឋានត្រូវស្ថិតនៅជិតកន្លែងធ្វើការ មានភាពងាយស្រួលដល់អ្នកជម្ងឺចេញចូល មានពន្លឺគ្រប់គ្រាន់ មានខ្យល់អាកាសល្អ នៅឆ្ងាយពីសម្លេងលាន់ឮខ្លាំង ឆ្ងាយពីទីតាំងដាក់កាកសំណល់ គ្មានធូលី គ្មានផ្សែង គ្មានក្លិន និងត្រូវមានទំហំសមស្របទៅតាមចំនួនកម្មករនិយោជិត ប៉ុន្តែយ៉ាងតូចបំផុតឱ្យមានផ្ទៃ ២០ម៉ែត្រក្រឡា ។

## ប្រការ៣.- អំពីចំនួននិងគុណភាពបុគ្គលិកសុខាភិបាល

ចំនួននិងគុណភាពនៃបុគ្គលិកសុខាភិបាល ត្រូវបានកំណត់ស្របតាមចំនួនកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថាន ដូចមានក្នុងតារាងខាងក្រោមនេះ ៖

| ចំនួនកម្មករនិយោជិតក្នុងសហគ្រាស | ចំនួនគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកា | ចំនួនគ្រូពេទ្យ | វត្តមានអប្បបរមារបស់គ្រូពេទ្យសំរាប់មួយថ្ងៃ៨ម៉ោង |
|---|---|---|---|
| ៥០ - ៣០០នាក់ | ១នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១នាក់ ឬ គ្រូពេទ្យមធ្យម១នាក់ | ២ម៉ោង |
| ៣០១ - ៦០០នាក់ | ១នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១នាក់ | ២ម៉ោង |
| ៦០១ - ៩០០នាក់ | ២នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១នាក់ | ៣ម៉ោង |
| ៩០១ - ១៤០០នាក់ | ២នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១នាក់ | ៤ម៉ោង |
| ១៤០១ - ២០០០នាក់ | ២នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១នាក់ | ៦ម៉ោង |
| លើសពី ២០០០នាក់ | ៣នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១នាក់ | ៨ម៉ោង |

កាលណាសហគ្រាស គ្រឹះស្ថាន មានធ្វើការបន្ថែមម៉ោង បុគ្គលិកនៃគិលានដ្ឋាន ត្រូវមានគិលានុបដ្ឋាក-យិកា និងគ្រូពេទ្យប្រចាំការក្នុងរយៈពេលធ្វើការបន្ថែមម៉ោងនេះ ។

ប្រការ៤.- អំពីសំភារៈ បរិក្ខារនិងឱសថ

សំភារៈជាគ្រឿងសង្ហារឹមត្រូវមានជាអប្បបរមាគឺ ៖

- តុធ្វើការមួយ
- កៅអីអង្គុយមានបង្អែកបី
- ទូសំរាប់ទុកដាក់ឯកសារមួយ
- ទូសំរាប់ដាក់តាំងឱសថមួយ
- គ្រែពីរមានពូកនិងកម្រាល
- បរិធានសម្រាប់រំងាប់មេរោគមួយ ( STERILISATEUR )

បរិក្ខារពេទ្យនិងឱសថ ត្រូវមានជាចាំបាច់ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាស នេះ ។

ប្រការ៥.- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតលើសពី ២០០នាក់ ត្រូវរៀបចំឱ្យមានគ្រែសំរាប់ឱ្យអ្នករបួសនិងអ្នកជម្ងឺសំរាក ទៅជិតគិលានដ្ឋានទៅតាមអត្រា ពីរភាគរយនៃចំនួនកម្មករនិយោជិតក្នុងសហគ្រាស គ្រឹះស្ថាន រហូតដល់ចំនួន២០គ្រែជាអតិបរមា ។

ប្រការ៦.- កាលណាសហគ្រាស គ្រឹះស្ថានមានសាខា ឬការដ្ឋានមួយឬច្រើនដែលមានកម្មករនិយោជិតចាប់ពី៥០នាក់ឡើងទៅ ហើយដែលស្ថិតនៅចម្ងាយលើសពី ប្រាំគីឡូម៉ែត្រ ពីការដ្ឋានធំនិយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះ ឱ្យដូចជាចំពោះការដ្ឋានធំដែរនូវមធ្យោបាយសង្គ្រោះនិងព្យាបាលកម្មករនិយោជិតខ្លួនឱ្យបានសព្វគ្រប់ដូចជា បុគ្គលិកពេទ្យ សំណង់ សំភារៈ វត្ថុរំរបួស និងឱសថព្យាបាល ។

ប្រការ៧.- ចំពោះសហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិតមិនដល់៥០នាក់ ត្រូវមានមធ្យោបាយសង្គ្រោះដូចខាងក្រោមនេះ ៖

-កម្មករនិយោជិតក្រោម២០នាក់ ត្រូវមានប្រអប់សង្គ្រោះមួយនិងអ្នកជំនួយសង្គ្រោះម្នាក់ ។

-កម្មករនិយោជិតពី២០ដល់៤៩នាក់ ត្រូវមានបន្ទប់រុំរបួសមួយ និងគិលានុបដ្ឋាក ឬគិលានុបដ្ឋាយិកាម្នាក់ ។

គ្រឿងសង្ហារឹម បរិក្ខារពេទ្យនិងឱសថដែលត្រូវមានជាចាំបាច់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ ។/.

ប្រការ៨.- អ្នកប្រព្រឹត្តិល្មើសនិងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែង ក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ៩.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

វេជ្ជ.ហុង_ស៊ុនហួត

រដ្ឋមន្ត្រី
ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

អ៊ិត សំហេង

ូងជូន :
ុទ្ទកាល័យព្រះមហាក្សត្រ
វត្តលេខាធិការដ្ឋានព្រឹទ្ធសភា
វត្តលេខាធិការដ្ឋានរដ្ឋសភា
ទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ស្តីការគណៈរដ្ឋមន្ត្រី
ាប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
ត្តនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
ើម្បីផ្សព្វផ្សាយនិងអនុវត្ត"
ប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
វយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
មាគមនិយោជក "ដើម្បីអនុវត្ត"
ហភាពសហជីព "ដើម្បីអនុវត្ត"
ប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
លប្បវត្តិ និងឯកសារ